01643048

D363/1.1.9

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៤/២/០៧-០៩-២០០៩-អវតក/អជសដ/ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អជសដ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 30 / 03 / 2020
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សំណើសាជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យអង្គជំនុំជម្រះសាលាដំបូង ចាត់វិធានការចាំបាច់ដើម្បីជំរុញសំណុំរឿង ០០៤/២ នៅជំនុំជម្រះ រួមទាំងបង្គាប់ឲ្យមាន ការបញ្ជូនសំណុំរឿង ០០៤/២ ជាបន្ទាន់ នៅកាន់អង្គជំនុំជម្រះសាលាដំបូង**

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J. Hollis
សហព្រះរាជអាជ្ញាអន្តរជាតិ

**ចម្លងជូន:**
លោកស្រី ជា លាង
សហព្រះរាជអាជ្ញាជាតិ

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Claudia FENZ
ចៅក្រម យ៉ា សុខន
ចៅក្រម Martin KAROPKIN
ចៅក្រម យូ ឧត្តរា

**សហមេធាវី អោ អាន**
លោក មុំ លុជ្ស
លោក Richard ROGERS
លោក Göran SLUITER

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២**

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សូមស្នើសាជាថ្មីនូវសំណើរបស់ខ្លួន សុំឲ្យអង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") បញ្ជាក់ថា ខ្លួនបានទទួលសំណុំរឿង០០៤/២ និងបង្គាប់ឲ្យសំណុំរឿងនេះត្រូវបានបញ្ជូនភ្លាមៗទៅកាន់ អ.ជ.ស.ដ[1]។ ស.ព.អ ធ្វើសំណើរបស់គាត់សាជាថ្មី ដោយគិតពីព័ត៌មាននាពេលថ្មីៗនេះ ដែលបានផ្តល់ជូនទៅភាគីដោយចៅក្រមនៃអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ដែលបានធ្វើឡើងយ៉ាងច្បាស់លាស់ថា អ.ប.ជ មិនមានការបំពេញកិច្ចអ្វីដែលត្រូវធ្វើបន្ថែមទៀតឡើយ។ ឥឡូវនេះគឺ អ.ជ.ស.ដ ត្រូវបំពេញកិច្ចដើម្បីជំរុញសំណុំរឿងនេះទៅជំនុំជម្រះ ដោយគ្មានការពន្យារពេល យោងតាមច្បាប់ អ.វ.ត.ក[2] វិធានផ្ទៃក្នុង("វិធាន")[3] និងគោលជំហរស្វ័យប្រវត្តិជាមូលដ្ឋាន និងជាកត្តាកំណត់ដែលឲ្យបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅជំនុំជម្រះ លើកលែងតែវាត្រូវបានបដិសេធដោយមតិភាគច្រើនលើសលុបរបស់ អ.ប.ជ។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អ.ប.ជ បានចេញសេចក្តីពិចារណារបស់ខ្លួនជាសាធារណៈ ពាក់ព័ន្ធនឹងដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងដែលផ្ទុយគ្នា ដែលបានចេញនៅក្នុងសំណុំរឿង ០០៤/២[4]។ អ.ប.ជ ខកខានមិនបានឈានដល់សំឡេងភាគច្រើនលើសលុបដែលបានតម្រូវ ដើម្បី

[1] *សូមមើល* សំណើដើមរបស់ ស.ព.អ នៅក្នុង ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ពាក់ព័ន្ធនឹងការប្តឹងឲ្យទទួលយកសំណុំរឿង០០៤/២ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២០ ("ចម្លើយតបរបស់ ស.ព.អ ស្តីពីការប្តឹងឲ្យទទួលយកសំណុំរឿង") កថាខណ្ឌ ២, ២២(i) ដែលត្រូវបានដាក់ជាសំណៅរឹងទៅកាន់ អ.ជ.ស.ដ៖ សំណើរបស់សហ ព្រះរាជអាជ្ញាអន្តរជាតិដែលថា អង្គជំនុំជម្រះសាលាដំបូងត្រូវបំពេញកិច្ច ដើម្បីឲ្យចូលមើលបាននូវសំណុំរឿង០០៤/២ (អោ អាន) ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ("សំណើរបស់ ស.ព.អ ស្តីពីការចូលមើល សំណុំរឿង") ដែលត្រូវបានដាក់ជាសំណៅរឹងទៅកាន់ អ.ជ.ស.ដ។

[2] ច្បាប់ស្តីពីការបង្កើតអោយមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដូចបានធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤("ច្បាប់ អ.វ.ត.ក") មាត្រា ២៣ថ្មី។

[3] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិ. លើកទី៩) ដូចដែលបានពិនិត្យសារឡើងវិញ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន") វិធាន ៧៧(១៣)(ខ)។

[4] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("សេចក្តីពិចារណា")។

បដិសេធលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ[5] ឬ ដីកាសម្រេចលើកលែងចោទប្រកាន់[6] ទេ។ សេចក្តីពិចារណានេះ ត្រូវបានជូនដំណឹងទៅកាន់ក្រឡាបញ្ជីនៃ អ.ជ.ស.ដ និង ចៅក្រមពីររូបនៃ អ.ជ.ស.ដ នៅថ្ងៃនោះ[7]។

3. បន្តបន្ទាប់មកទៀត ភាគីនានាបានដាក់ចម្លើយតបមុនសវនាការមួយចំនួន ទៅ អ.ជ.ស.ដ[8] ដែលអមដោយសារអេឡិចត្រូនិកមួយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ពីក្រឡាបញ្ជី អ.ជ.ស.ដ ដោយថ្លែងថា ទាំងសំណុំរឿង និងទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានបញ្ជូនមក អ.ជ.ស.ដ ទេ[9]។ បន្ទាប់មក ស.ព.អ និង អោ អាន បានធ្វើសារណាជាលាយលក្ខណ៍អក្សរមួយចំនួន ទៅ អ.ប.ជ ពាក់ព័ន្ធនឹងស្ថានភាពនៃការបញ្ជូនសំណុំរឿង០០៤/២ ដែលសារណាទាំងអស់នោះត្រូវបានធ្វើឡើងជាសាធារណៈ[10]។ មកដល់ថ្ងៃនេះ មិនមានការចាត់វិធានការណាមួយ ត្រូវបានធ្វើឡើងចំពោះសំណើទាំងនេះទេ។

4. នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ក្រឡាបញ្ជី អ.ជ.ស.ដ បានជម្រាបជាព័ត៌មានដល់ភាគីនានា តាមរយៈសារអេឡិចត្រូនិកថា បើទុកណាជា អ.ជ.ស.ដ បានដឹងពីសេចក្តីពិចារណាដែលអាចមានជាសាធារណៈក៏ដោយ ក៏ខ្លួននៅតែមិនទាន់ត្រូវបាន *ជូនដំណឹងជាផ្លូវការ* ពីសេចក្តីពិចារណានោះដោយ អ.ប.ជ នៅឡើយទេ ហើយសំណុំរឿងនោះក៏មិនត្រូវបានបញ្ជូនដែរ។ សារអេឡិចត្រូនិកនេះបានបញ្ជាក់សេចក្តីថា អ.ប.ជ ត្រូវតែផ្តួចផ្តើមនូវសកម្មភាពទាំងនោះ[11]។

---

[5] ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

[6] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាសម្រេចលើកលែងចោទប្រកាន់")។

[7] *សូមមើល* អ៊ីមែលស្តីពីការជូនដំណឹងពីមន្ត្រីកាន់សំណុំរឿង ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ម៉ោង៖ ៤:៥៣ រសៀល ដែលត្រូវបានដាក់ពីមុនជូនទៅ អ.ជ.ស.ដ ជាឧបសម្ព័ន្ធ ខ ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបញ្ជាក់ពីអ៊ីមែលថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ របស់អង្គជំនុំជម្រះសាលាដំបូង (ដោយមានឧបសម្ព័ន្ធសាធារណៈពី ក-ច) ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០។ អ៊ីមែលស្តីពីការជូនដំណឹងពីបញ្ជីចែកចាយ មានរាប់បញ្ចូលផងដែរនូវ ចៅក្រម អ.ជ.ស.ដ ពីររូបគឺ៖ ចៅក្រម Claudia Fenz និងចៅក្រម Martin Karopkin និង ក្រឡាបញ្ជី អ.ជ.ស.ដ។

[8] *សូមមើល* ឧបសម្ព័ន្ធ-ក កថាខណ្ឌ ២-៥ សម្រាប់សេចក្តីពិស្តារ។

[9] *សូមមើល* ឧបសម្ព័ន្ធ-ក កំណត់សម្គាល់ជើងទំព័រលេខ ១២ សម្រាប់សេចក្តីពិស្តារ។

[10] *សូមមើល* ឧបសម្ព័ន្ធ-ក កំណត់សម្គាល់ជើងទំព័រលេខ ១៣ សម្រាប់សេចក្តីពិស្តារ។

[11] អ៊ីមែលក្រោមចំណងជើងថា "ពាក់ព័ន្ធនឹងសំណើរបស់ ស.ព.អ ចុះកាលបរិច្ឆេទថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០" ផ្ញើចេញដោយក្រឡាបញ្ជី អ.ជ.ស.ដ និង មន្ត្រីច្បាប់ លឹម ស៊ុយហុង ក្នុងនាម អ.ជ.ស.ដ កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ នៅម៉ោង៖

5. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ សហព្រះរាជអាជ្ញា សហមេធាវី អោ អាន និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី បានទទួលតាមរយៈសារអេឡិចត្រូនិក នូវអនុស្សរណៈអន្តរការិយាល័យមួយពីចៅក្រមអន្តរជាតិនៃ អ.ប.ជ ដោយបានសរសេរថា "ការបញ្ជូនសំណុំរឿង០០៤/២" ជាប្រធានបទ[12]។ អនុស្សរណៈនេះ ("អនុស្សរណៈ ថ្ងៃទី១២ ខែមីនា") បានរៀបរាប់យ៉ាងពិស្ដារនូវភាពជាប់គាំងខាងផ្នែកនីតិវិធី ដែលត្រូវបានកើតឡើងនៅក្រោយឆាកនៅក្នុង អ.ប.ជ និងការិយាល័យរដ្ឋបាល ដែលភាគីនានាមិនដែលបានដឹងពីមុនមក[13]។

6. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ លោកប្រធាន អ.ប.ជ បានចេញអនុស្សរណៈមួយ ជូនមកសហព្រះរាជអាជ្ញា សហមេធាវី អោ អាន និង មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ("អនុស្សរណៈ ថ្ងៃទី១៦ ខែមីនា") ដោយបញ្ជាក់យ៉ាងច្បាស់តាមការប៉ាន់ស្មានរបស់គាត់ថា អ.ប.ជ "បានបំពេញកាតព្វកិច្ចរបស់ខ្លួនទៅតាមច្បាប់រួចរាល់ហើយ" ហើយមិនមានវិធានការរដ្ឋបាលបន្ថែមទៀតដែលតម្រូវឱ្យ អ.ប.ជ ត្រូវបំពេញនោះទេ[14]។

7. ប្រវត្តិនីតិវិធីពាក់ព័ន្ធទាំងស្រុង ត្រូវបានរៀបរាប់យ៉ាងពិស្ដារ នៅក្នុងឧបសម្ព័ន្ធ ក។

## III. ច្បាប់ជាធរមាន

8. ស.ព.អ បានដាក់បញ្ចូលគ្នា ដោយការយោងនូវច្បាប់ជាធរមាន ដែលមានចែងនៅក្នុងសំណើដើមរបស់ខ្លួន ជូនទៅ អ.ជ.ស.ដ[15] និង សេចក្ដីពិស្ដារបន្ថែមទៀតនៅខាងក្រោមនេះ។

## IV. សេចក្ដីសន្និដ្ឋាន

---

១១:៤៤ ព្រឹក ជូនទៅ សហព្រះរាជអាជ្ញា និង មេធាវីរបស់ អោ អាន ដោយបានចម្លងជូនចៅក្រម អ.ប.ជ ក៏ដូចជាលោកប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលផងដែរ ("អ៊ីមែលរបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០")។

[12] អនុស្សរណៈអន្តរការិយាល័យពីចៅក្រម Beauvallet និង Baik នៃ អ.ប.ជ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ("អនុស្សរណៈ ថ្ងៃទី១២ ខែមីនា")។ អនុស្សរណៈនេះ ត្រូវបានអ៊ីមែលទៅកាន់ក្រឡាបញ្ជី អ.ជ.ស.ដ និងត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធផងដែរ ទៅនឹង សំណើសាជាថ្មីនេះ រួមជាមួយនឹងឯកសារភ្ជាប់ចំនួន ៨ របស់វា។

[13] *សូមមើល* ឧបសម្ព័ន្ធ-ក កថាខណ្ឌ ៨-១១ សម្រាប់សេចក្ដីពិស្ដារ។

[14] អនុស្សរណៈពីចៅក្រម ប្រាក់ គឹមសាន ជូនទៅ ការិយាល័យសហព្រះរាជអាជ្ញា មេធាវីការពារក្ដីរបស់ អោ អាន និង មេធាវីការពារក្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៃសំណុំរឿង០០៤/២ ក្រោមចំណងជើងថា "សេចក្ដីបញ្ជាក់ឡើងវិញពីសេចក្ដីសម្រេចលើសំណុំរឿង០០៤/២" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ("អនុស្សរណៈថ្ងៃទី១៦ ខែមីនា") កថាខណ្ឌ ៥។

[15] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា អង្គជំនុំជម្រះសាលាដំបូងត្រូវបំពេញកិច្ច ដើម្បីឱ្យចូលមើលបាននូវសំណុំរឿង០០៤/២ (អោ អាន) ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០។

9. ការបន្តការពន្យារពេលរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការស្វែងរកដំណោះស្រាយដែលអាចមានចំពោះរឿងក្តីនេះដោយ អ.ប.ជ លែងធ្វើបានហើយ[16]។ អនុស្សរណៈចំនួនពីរដែលបានចេញដោយចៅក្រម អ.ប.ជ នាពេលថ្មីៗនេះ និងដែលបានពិភាក្សាយ៉ាងពេញលេញនៅក្នុង ឧបសម្ព័ន្ធ ក បញ្ជាក់ថា អ.ប.ជ នៅក្នុងគំនិតរបស់គាត់ "បានបំពេញកាតព្វកិច្ចរបស់គាត់" រួចហើយ ហើយក៏មិនមានវិធានការផ្នែករដ្ឋបាលបន្ថែមទៀត ពាក់ព័ន្ធនឹងការបញ្ជូនសំណុំរឿង០០៤/២ នេះដែរ[17]។

10. បើទុកណាជាលោកប្រធាន អ.ប.ជ បានរាំងខ្ទប់ជាឯកតោភាគីនូវ *ការជូនដំណឹងជាផ្លូវការ* និង *ការបញ្ជូនបែបរូបវ័ន្ត* នូវសំណុំរឿង ០០៤/២ ទៅ អ.ជ.ស.ដ ក៏ដោយ ក៏ ស.ព.អ នៅតែប្រកាន់ជំហររបស់ខ្លួនថា ទាំងនេះគឺគ្រាន់តែជាវិធានការរដ្ឋបាលប៉ុណ្ណោះ[18]។ ស.ព.អ នៅតែប្រកាន់ជំហររបស់ខ្លួនថា អ.ជ.ស.ដ គឺតាមច្បាប់ ត្រូវ*បានប្តឹងឲ្យទទួលយក* នូវសំណុំរឿង ០០៤/២ តាមវិធាន ៧៧(១៣)(ខ) និង ៧៩(១) ចាប់តាំងពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ មកម្ល៉េះ[19]។ ការជូនដំណឹងជាផ្លូវ

---

[16] *សូមមើល* កថាខណ្ឌ ៤ *ខាងលើ* ដែលបានយោងទៅ អ៊ីមែលរបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ក្នុងនាម អ.ជ.ស.ដ ដោយបាននិយាយថា វាអាស្រ័យលើ អ.ប.ជ ដើម្បីផ្តួចផ្តើមការបំពេញកិច្ចក្នុងការបញ្ជូនសំណុំរឿង ០០៤/២ ទៅកាន់ អ.ជ.ស.ដ។

[17] *សូមមើល* កថាខណ្ឌ ៥-៦ *ខាងលើ។ សូមមើលផងដែរ* ឧបសម្ព័ន្ធ ក កថាខណ្ឌ ៨-១១ (អនុស្សរណៈថ្ងៃទី១២ ខែមីនា បង្ហាញថា នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ចៅក្រម អ.ប.ជ បានចេញដីកាសម្រេចផ្ទុយគ្នា ទៅកាន់អង្គភាពប័ណ្ណសារ ("RAU") ដែលបណ្តាលឲ្យ RAU ស្វែងរកការបញ្ជាក់ថាតើសេចក្តីណែនាំមួយណាដែលខ្លួនត្រូវធ្វើតាម។ ប្រធាន អ.ប.ជ បានថ្លែងថា ការជូនដំណឹងទៅកាន់បុគ្គល ឬ អង្គជំនុំជម្រះណា ដែលមិនមែនជាភាគីទៅនឹងសំណុំរឿង គឺបានរំលោភលើសេចក្តីសម្រេចជាឯកច្ឆ័ន្ទរបស់ អ.ប.ជ។ បន្ទាប់មក គាត់បានចេញអនុស្សរណៈ ថ្ងៃទី១៦ ខែមីនា ដើម្បីនិយាយជាផ្តាច់ព្រ័តថា មិនមានការបំពេញកិច្ចតាមបែបរដ្ឋបាលបន្ថែមទៀតទេ)។

[18] *សូមមើល* ឧបសម្ព័ន្ធ ក កថាខណ្ឌ ៨-១១, ១៧ សម្រាប់សេចក្តីពិស្តារ។ *សូមមើលផងដែរ* អនុស្សរណៈថ្ងៃទី១២ ខែមីនា កថាខណ្ឌ ៣៦ ដែលចៅក្រមអន្តរជាតិ អ.ប.ជ បាននិយាយថា "ឥឡូវនេះ វាអាស្រ័យលើអង្គជំនុំជម្រះសាលាដំបូងធ្វើការពិនិត្យឡើងវិញតាមផ្លូវតុលាការរបស់ខ្លួន នូវសំណុំរឿងដែលនៅក្នុងដៃនេះ ដែលត្រូវបានបញ្ជូនទៅឲ្យខ្លួន ពីអង្គបុរេជំនុំជម្រះដោយមិនគិតពីកាតព្វកិច្ចរបស់ក្រឡាបញ្ជីដែលអមការបញ្ជូននេះទេ"។

[19] *សូមមើល* សារណារបស់ ស.ព.អ ដាក់ជូនទៅ អ.ជ.ស.ដ និង អ.ប.ជ ដោយបានពិភាក្សាពីរឿងនេះ ទាំងស្រុងជាងនេះ - **អ.ជ.ស.ដ៖** ចម្លើយតបរបស់ ស.ព.អ ស្តីពីការប្តឹងឲ្យទទួលយកសំណុំរឿង។ សំណើរបស់ ស.ព.អ ស្តីពីការចូលមើលសំណុំរឿង។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសេចក្តីសង្ខេបរបស់ អោ អាន ស្តីពីអញ្ញត្រកម្ម តាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ("ចម្លើយតបទៅនឹងអញ្ញត្រកម្មរបស់ ស.ព.អ")។ **អ.ប.ជ៖** ឯកសារ **D359/25 & D360/34** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យចាត់រាល់វិធានការរដ្ឋបាលដែលតម្រូវ ទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ("សំណើ សុំវិធានការរដ្ឋបាលរបស់ ស.ព.អ")។ ឯកសារ **D359/28 & D360/37** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ ស្នើសុំឲ្យចាត់រាល់វិធានការរដ្ឋបាលទាំងអស់ដែលចាំបាច់ដើម្បីបញ្ជូនសំណុំរឿង០០៤/២

ការ និងជារូបវ័ន្ត នៃការបញ្ជូនសំណុំរឿង គឺជាការចាត់វិធានការតាមបែបរដ្ឋបាល *អាស្រ័យដោយ* អ.ជ.ស.ដ មានយុត្តាធិការ គឺមិនមែនធ្វើដើម្បី *ប្រគល់* យុត្តាធិការ នោះទេ។

11. បន្ថែមលើនេះ ខណៈដែលសារអេឡិចត្រូនិក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រឡាបញ្ជី អ.ជ.ស.ដ ទំនងជាលើកឡើងថា អ.ជ.ស.ដ អាចនឹងត្រូវ *បានប្ដឹងឲ្យទទួលយក*សំណុំរឿង០០៤/២ តែនៅពេលណា អ.ប.ជ បានផ្ដួចផ្ដើមនូវវិធានការរដ្ឋបាលដូច្នេះ[20]មែននោះ ស.ព.អ សុំសួរថា ហេតុអ្វីបានជាវិធានការដែលមានលក្ខណៈគ្រប់គ្រាន់ដូចគ្នានេះ ដែលត្រូវបានប្ដឹងឲ្យអង្គជំនុំជម្រះសាលាដំបូងដដែលនេះ ទទួលយកនៅក្នុងសំណុំរឿង ០០១ និង ០០២ បែរជាមិនគ្រប់គ្រាន់នៅក្នុងសំណុំរឿង ០០៤/២[21] ដែលគេមិនអាចពន្យល់បានយ៉ាងដូច្នេះទៅវិញ។ រហូតមកទល់ពេលនេះ ស.ព.អ មិនដែលបានទទួលការបញ្ជាក់បំភ្លឺណាមួយទេ។ ស.ព.អ សន្និដ្ឋានថា ការផ្លាស់ប្ដូរដូច្នេះនៅក្នុងលក្ខខណ្ឌតម្រូវនៃកិច្ចដំណើរការនីតិវិធី ដោយមិនមានការជូនដំណឹងដូច្នេះ គឺបានរំលោភលើគោលការណ៍ជាក់លាក់នៃនីត្យានុកូលភាព និងគោលការណ៍តម្លាភាពនៃកិច្ចដំណើរការនីតិវិធី ក៏ដូចជាសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្ដីដោយត្រឹមត្រូវយុត្តិធម៌ ដែលត្រូវបានធានាចំពោះ *គ្រប់ភាគីទាំងអស់*[22]។

12. ស.ព.អ ដាក់បញ្ចូលអំណះអំណាងពីមុនរបស់ខ្លួនតាមរយៈសេចក្ដីយោង និងនៅតែប្រកាន់ជំហរថា៖

---

(អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ ("ការឆ្លើយតបទៅនឹងវិធានការរដ្ឋបាលរបស់ ស.ព.អ")។ ឯកសារ **D359/30 & D360/39** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង សំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថាវិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង០០៤/២ ទុកក្នុងប័ណ្ណសារ ចុះថ្ងៃទី ៥ ខែមីនា ឆ្នាំ២០២០ ("ចម្លើយតបស្ដីពីបណ្ណសាររបស់ ស.ព.អ")។ *សូមមើលផងដែរ* អនុស្សរណៈថ្ងៃទី១២ ខែមីនា កថាខណ្ឌ ១២ និងឯកសារភ្ជាប់លេខ ៦ នៃអនុស្សរណៈថ្ងៃទី១២ ខែមីនា ដោយឡែកទំព័រទី ៤-៦។

[20] *សូមមើល* កថាខណ្ឌ ៤ *ខាងលើ*។

[21] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យបញ្ជាក់ពីអ៊ីមែលថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ របស់អង្គជំនុំជម្រះសាលាដំបូង (ដោយមានឧបសម្ព័ន្ធពី ក-ច) ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ កថាខណ្ឌ ២០-២៦, ២៩ ដែលត្រូវបានដាក់ជាសំណៅរឹង ជូនទៅក្រឡាបញ្ជី អ.ជ.ស.ដ។

[22] *សូមមើល ឧទា.* កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ១២(២)។ ច្បាប់ អ.វ.ត.ក មាត្រា ៣៣ថ្មី។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

(i) វិធាន ៧៧(១៣)(ខ) តាមគោលជំហរស្វ័យប្រវត្តិរបស់វា ត្រូវបានបញ្ចេះឲ្យផ្តើមធ្វើការងាររបស់វាហើយ ដោយសារតែ អ.ប.ជ មិនអាចស្វែងរកសំឡេងភាគច្រើនលើសលុបតាមលក្ខខណ្ឌតម្រូវដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ[23]។

(ii) វិធាន ៧៧(១៣)(ខ) មានអនុភាពលុបលើពាក្យពេចន៍ស្វ័យប្រវត្តិទូទៅដែលមានចែងនៅក្នុងវិធាន ៧៧(១៣)(ក) ដោយសារទ្រឹស្តី *ច្បាប់ជាក់លាក់ (lex specialis)* និងភាពស្របគ្នាទៅនឹងគោលជំហរស្វ័យប្រវត្តិដែលមានចែងក្នុងកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក[24]។

(iii) នៅក្នុងគោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនអាចអនុវត្តបានទេសម្រាប់រឿងក្តីនេះ[25]។ ហើយ

(iv) អ.ប.ជ បានសង្កត់ធ្ងន់ជាឯកច្ឆន្ទថា គោលជំហរស្វ័យប្រវត្តិនេះ "មិនអាចលុបលើ ឬដកហូតទម្ងន់ និងអនុភាពដ៏ពេញលេញរបស់វាតាមរយៈការសន្មតបែបបកស្រាយមួលបង្កាច់" ឬ តាមរយៈ "ការកៃយកចំណេញពីភាពមិនច្បាស់លាស់ណាមួយនៅក្នុងច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ដើម្បីធ្វើឲ្យគោលការណ៍ស្នូលនៃកិច្ចព្រមព្រៀង អ.វ.ត.ក ប្រែជាគ្មានន័យឡើយ"[26]។ អង្គជំនុំជម្រះដែលមានការឯកភាពគ្នាជាឯកច្ឆន្ទនេះ បានពន្យល់បន្ថែមថា

---

[23] ចម្លើយតបរបស់ ស.ព.អ ស្តីពីការប្តឹងឲ្យទទួលយកសំណុំរឿង, កថាខណ្ឌ ៩-១៥។ សំណើសុំសិទ្ធិចូលពិនិត្យមើលសំណុំរឿងរបស់ ស.ព.អ, កថាខណ្ឌ ២៤។ ឯកសារ **D359/25 & D360/34** សំណើសុំវិធានការរដ្ឋបាលរបស់ ស.ព.អ, កថាខណ្ឌ ២៣។ ឯកសារ **D359/28 & D360/37** ការឆ្លើយតបទៅនឹងវិធានការរដ្ឋបាលរបស់ ស.ព.អ, កថាខណ្ឌ ២-៥។ ឯកសារ **D359/30 & D360/39** ចម្លើយតបស្តីពីប័ណ្ណសាររបស់ ស.ព.អ, កថាខណ្ឌ ១២-១៥។ ចម្លើយតបទៅនឹងអញ្ញត្រកម្មរបស់ ស.ព.អ, កថាខណ្ឌ ៨-១០។

[24] ឯកសារ **D359/25 & D360/34** សំណើសុំវិធានការរដ្ឋបាលរបស់ ស.ព.អ, កថាខណ្ឌ ២, ២៥។ ឯកសារ **D359/28 & D360/37** ការឆ្លើយតបទៅនឹងវិធានការរដ្ឋបាលរបស់ ស.ព.អ, កថាខណ្ឌ ៣។ ឯកសារ **D359/30 & D360/39** ចម្លើយតបស្តីពីប័ណ្ណសាររបស់ ស.ព.អ, កថាខណ្ឌ ១៣។ សំណើសុំសិទ្ធិចូលពិនិត្យមើលសំណុំរឿង របស់ ស.ព.អ, កថាខណ្ឌ ២៤។ ចម្លើយតបរបស់ ស.ព.អ ស្តីពីការប្តឹងឲ្យទទួលយកសំណុំរឿង, កថាខណ្ឌ ១០។ ចម្លើយតបទៅនឹងអញ្ញត្រកម្មរបស់ ស.ព.អ, កថាខណ្ឌ ១០។

[25] ចម្លើយតបរបស់ ស.ព.អ ស្តីពីការប្តឹងឲ្យទទួលយកសំណុំរឿង, កថាខណ្ឌ ១៦-១៩។ ឯកសារ **D359/28 & D360/37** ការឆ្លើយតបទៅនឹងវិធានការរដ្ឋបាលរបស់ ស.ព.អ, កថាខណ្ឌ ៦-៨។ ឯកសារ **D359/30 & D360/39** ចម្លើយតបស្តីពីប័ណ្ណសាររបស់ ស.ព.អ, កថាខណ្ឌ ១៦។ ចម្លើយតបទៅនឹងអញ្ញត្រកម្មរបស់ ស.ព.អ, កថាខណ្ឌ ១២-១៥។

[26] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណា, កថាខណ្ឌ ១១២។ *សូមមើលផងដែរ* ចម្លើយតបរបស់ ស.ព.អ ស្តីពីការប្តឹងឲ្យទទួលយកសំណុំរឿង, កថាខណ្ឌ ១០។ ឯកសារ **D359/25 & D360/34** សំណើសុំវិធានការរដ្ឋបាលរបស់ ស.ព.អ, កថាខណ្ឌ ២៦។ ចម្លើយតបទៅនឹងអញ្ញត្រកម្មរបស់ ស.ព.អ, កថាខណ្ឌ ៩។

គោលបំណងនៃគោលជំហរស្វ័យប្រវត្តិនេះ គឺដើម្បីធានាឲ្យមាន "យុត្តិធម៌ប្រកបដោយប្រសិទ្ធិភាព" និងដើម្បី "បញ្ចៀសភាពជាប់គាំងផ្នែកនីតិវិធី ដែលនឹងធ្វើមានឧបសគ្គដល់ប្រសិទ្ធិភាពនៃកិច្ចដំណើរការនីតិវិធី[27] ជាដើម។

13. គួរឲ្យសោកស្ដាយ អនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា និងអនុស្សរណៈ ចុះថ្ងៃទី១៦ ខែមីនា បង្ហាញឲ្យឃើញថា ប្រធាន អ.ប.ជ មានចេតនារារាំងចំណាត់ការរដ្ឋបាលក្នុងការបញ្ជូនសំណុំរឿងនេះទៅ អ.ជ.ស.ដ ដែលជាអង្គជំនុំជម្រះដែលត្រូវបានប្ដឹងឲ្យទទួលយកសំណុំរឿងនេះ។ ទោះជាយ៉ាងណា សកម្មភាពដូច្នេះមិនអាចបញ្ចៀសការអនុវត្តគោលជំហរស្វ័យប្រវត្តិបានឡើយ - ព្រោះថាបើយើងអនុញ្ញាតឲ្យវាកើតឡើង នោះការមិនចាត់ការរបស់ អ.ប.ជ នឹងនាំឲ្យមាន "លទ្ធផលផ្លូវច្បាប់ដែលគ្មានហេតុផលជាក់ស្ដែង"[28]។ ហេតុដូចនេះ ស.ព.អ សូមស្នើជាថ្មីឲ្យ អ.ជ.ស.ដ ចាត់វិធានការស្របតាមការប្ដឹងឲ្យទទួលយកនៃសំណុំរឿងនេះ តាមរយៈការបង្គាប់ឲ្យបញ្ជូនសំណុំរឿងនេះជាបន្ទាន់ទៅ អ.ជ.ស.ដ។

14. ដូចបានកំណត់ពីមុន តាមក្រមសីលធម៌គឺ អ.ជ.ស.ដ ត្រូវមានកាតព្វកិច្ចស្របតាមក្រមសីលធម៌តុលាការរបស់ អ.វ.ត.ក និងគោលការណ៍ជាមូលដ្ឋានរបស់ អ.ស.ប ស្ដីពីឯករាជ្យភាពរបស់តុលាការ ដើម្បីសម្រេចលើបញ្ហាដែលអាចសម្រេចបាននៅចំពោះមុខខ្លួន[29] ដោយឯករាជ្យ និងចាកផុតពីឥទ្ធពលខាងក្រៅនានា[30]។

15. យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") ក៏ផ្ដល់អាណត្តិឲ្យ អ.ប.ជ ចាត់វិធានការផងដែរ។ អ.ជ.ត.ក បានថ្លែងថា ដើម្បីធានាឲ្យមានសវនាការមួយត្រឹមត្រូវយុត្តិធម៌ និងដើម្បីបំពេញបាននូវបេសកកម្មតុលាការឲ្យបានត្រឹមត្រូវ អង្គស្ថាប័នតុលាការរបស់ អ.វ.ត.ក ទាំងអស់ ត្រូវតែមានអំណាចចាំបាច់សម្រាប់រក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងត្រូវគោរព

---

[27] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណា, កថាខណ្ឌ ១១១។

[28] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណា, កថាខណ្ឌ ១១២។

[29] ចំណុចនេះមានចែងយ៉ាងលម្អិតនៅក្នុង ("ចម្លើយតបរបស់ ស.ព.អ ស្ដីពីការប្ដឹងឲ្យទទួលយកសំណុំរឿង"), កថាខណ្ឌ ១៥។ *សូមមើលផងដែរ* សារអេឡិចត្រូនិកមានចំណងជើងថា "ព័ត៌មាន" ដែលបានបញ្ជូនដោយ ស៊ុយ ហុងលឹម ក្នុងនាម អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ នៅម៉ោង ១:៤៨នាទី រសៀល ដោយទទួលស្គាល់ពីការទទួលបានឯកសារដែលបានបញ្ជូនដោយភាគីជូនទៅ អ.ជ.ស.ដ។

[30] ច្បាប់ អ.វ.ត.ក, មាត្រា ១០ថ្មី។

ចំពោះយុត្តិធម៌*គ្រប់ពេលវេលាទាំងអស់*[31]។ តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ក៏ទទួលស្គាល់អំណាចរបស់អង្គជំនុំជម្រះក្នុងការប្រើប្រាស់នូវយុត្តាធិការដែលជាប់មកជាមួយរបស់ខ្លួន ដើម្បីសម្រេចលើបញ្ហាណាមួយក្នុងពេលអវត្តមាននៃបទប្បញ្ញត្តិច្បាប់ រួមទាំងក្នុងពេលដែលតុលាការគ្មានអំណាចក្នុងការប្រកាសលើបញ្ហានោះផង អាស្រ័យដោយភាពប្រទាស់ប្រទែងផ្លូវច្បាប់ ឬឧបសគ្គផ្នែកអនុវត្ត" ក្នុងពេលចាំបាច់ត្រូវដោះស្រាយនូវចន្លោះប្រហោងណាមួយ ដែលអាចមាននៅក្នុងកិច្ចដំណើរការនីតិវិធី ឬនៅក្នុងពេលដែលតុលាការមានតម្រូវការដើម្បីធានាថា យុត្តិធម៌មិនត្រឹមតែធ្វើបានសម្រេចប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវបានគេ*មើលឃើញ* ថានឹងសម្រេចបាន[32]។ ដោយ

---

[31] សំណុំរឿង ០០២-ឯកសារ **E116/1/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២, កថាខណ្ឌ ៣០ (អ.ស.ត.ក ក៏បានថ្លែងផងដែរថាវាត្រូវបាន "បង្កើតឡើងយ៉ាងរឹងមាំនៅកម្រិតអន្តរជាតិ" ដែលអំណាចសម្រាប់ដោះស្រាយជាមួយ "ការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ" ត្រូវបានប្រគល់ទៅឲ្យតុលាការ "ដោយសារតែជាតួនាទីផ្នែកតុលាការ")។

[32] *សូមមើល ឧ. នៅក្នុងបញ្ហារបស់* *El Sayed*, CH/AC/2010/02, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមអង្គបុរេជំនុំជម្រះ ទាក់ទងនឹងយុត្តាធិការ និងសិទ្ធិប្តឹង, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០, កថាខណ្ឌ ៤៥ ("[យុត្តាធិការជាប់មកជាមួយ] អាចប្រើបាន ជាពិសេស នៅពេលដែលគ្មានតុលាការផ្សេងមានអំណាចប្រកាសលើបញ្ហាច្បាប់ដែលកើតឡើងដោយចៃដន្យ ដោយសារភាពប្រទាស់ប្រទែងផ្នែកច្បាប់ ឬឧបសគ្គក្នុងការអនុវត្ត។ ដូច្នេះ យុត្តាធិការជាប់មកជាមួយនេះ គឺជាការងារបន្ទាប់បន្សំ ឬជាភាពចៃដន្យចំពោះយុត្តាធិការចំបង ហើយចាំបាច់តាមតម្រូវកំណត់ដើម្បីធានាដល់រដ្ឋបាលតុលាការមួយដែលល្អ និងត្រឹមត្រូវយុត្តិធម៌ រួមទាំងការគោរពយ៉ាងពេញលេញចំពោះសិទ្ធិមនុស្សជាធរមានចំពោះជនទាំងឡាយដែលមានការពាក់ព័ន្ធក្នុងកិច្ចដំណើរការនីតិវិធី នៅក្នុងតុលាការដែលមានយុត្តាធិការឆាប់រហ័ស"),កថាខណ្ឌ ៤៦, ៤៨ ("ការអនុវត្តរបស់ស្ថាប័នតុលាការអន្តរជាតិបង្ហាញថា វិធានដែលផ្តល់ដល់តុលាការអន្តរជាតិនូវយុត្តាធិការជាប់មកជាមួយ មានគោលដៅទូទៅក្នុងការដោះស្រាយចន្លោះប្រហោងដែលអាចមាននៅក្នុងបទប្បញ្ញត្តិច្បាប់ស្តីពីកិច្ចដំណើរការនីតិវិធី")។ *រដ្ឋអាជ្ញា ទល់នឹង Blagojević & Jokić*, IT-02-60-T, សេចក្តីសម្រេចស្តីពីមេធាវីការពារក្តីឯករាជ្យ សម្រាប់ញត្តិស្នើសុំរបស់ Vidoje Blagojevic ដើម្បីណែនាំឲ្យអ្នកកាន់បញ្ជីតែងតាំងសហមេធាវីនាំមុខថ្មី, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៣, កថាខណ្ឌ ១១២, ១១៤ (អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អះអាងថា ខណៈដែលខ្លួនមិនតម្រូវឲ្យចាត់វិធានការបន្ថែមណាមួយក្តី តែខ្លួនមានផលប្រយោជន៍ និងការប្តេជ្ញាចិត្តជារួមដើម្បីធានាថា "យុត្តិធម៌មិនត្រឹមតែធ្វើបានសម្រេចប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវបានគេ*មើលឃើញ* ថានឹងសម្រេចបាន"។ អាស្រ័យហេតុនេះ ខ្លួនបានបង្គាប់ឲ្យមានវិធានការពិសេសដែលនឹងតំណាងយ៉ាងពេញលេញដល់ផលប្រយោជន៍របស់ជនជាប់ចោទ)។ *រដ្ឋអាជ្ញា ទលនឹង Beqaj*, IT-03-66-T-R77, សាលក្រមលើការចោទប្រកាន់អំពីការប្រមាថ, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៥, កថាខណ្ឌ ៩ ("អង្គជំនុំជម្រះរបស់តុលាការនេះ បានបញ្ជាក់អះអាងស្របគ្នាអំពីអំណាចជាប់មកជាមួយរបស់តុលាការ ដែលមានអត្ថិភាពដោយឯករាជ្យពីសេចក្តីយោងនៃច្បាប់ណាមួយ ក្នុងការដាក់ទណ្ឌកម្មចំពោះទង្វើប្រព្រឹត្តដែលមានបំណងរារាំង ធ្វើឲ្យខូច ឬរំលោភលើរដ្ឋបាលតុលាការរបស់តុលាការនេះ")។ អំណាចនេះគឺចាំបាច់ដើម្បីធានាថា ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់តុលាការ មិនមានបញ្ហា ហើយមុខងារតុលាការជាមូលដ្ឋានរបស់តុលាការ ត្រូវបានការពារ"), កថាខណ្ឌ ១០-១២ (ហើយនឹងយុត្តិសាស្ត្រដែលបានយោងនៅក្នុងនោះ), កថាខណ្ឌ ១៣ ("ចៅក្រមនៃតុលាការនេះ ប្រើអំណាចជាប់មកជាមួយដើម្បីចាត់វិធានការចាំបាច់ដើម្បីធានាអំពីសុចរិតភាពនៃ

សារកាលៈទេសៈទាំងអស់នេះអាចអនុវត្តបានចំពោះស្ថានភាពពេលនេះ នៅក្នុងសំណុំរឿង០០៤/២ នោះ អ.ជ.ស.ដ ត្រូវតែប្រើយុត្តាធិការដែលមានជាប់មកជាមួយរបស់ខ្លួន "ដើម្បីសម្រេចបញ្ចប់លើបញ្ហាច្បាប់ដែលមាននៅចំពោះមុខខ្លួនឱ្យបានដាច់ស្រេច" និងដោះស្រាយលើ "បញ្ហាជាសារធាតុ និង/ឬ បញ្ហា*នីតិវិធី*"[33]។

16. ជាការពិតណាស់ ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ អ.ជ.ស.ដ ត្រូវសម្រេចលើបញ្ហានេះ និងធ្វើឱ្យសំណុំរឿងនេះធ្វើដំណើរទៅជំនុំជម្រះ ដោយហេតុថា ការមិនចាត់ការនឹងធ្វើឱ្យមានការផ្អាកកិច្ចដំណើរការនីតិវិធី*តាមព្រឹត្តន័យ* ដែលនឹងរំលត់យ៉ាងមានប្រសិទ្ធិភាពទៅលើករណីនេះដោយគ្មានការពន្យល់ និងក្រៅក្រសែភ្នែករបស់សាធារណជន។ មូលដ្ឋានសម្រាប់រំលត់ករណីដូច្នេះមិនអនុញ្ញាតឡើយនៅក្រោមច្បាប់នីតិវិធីកម្ពុជា និងបារាំង ឬយុត្តិសាស្ត្រអន្តរជាតិ[34]។

17. ជាចុងក្រោយ ដោយសារមិនទាន់មានការចាត់តាំងលេខសំណុំរឿង ចំពោះកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០៤/២ នៅចំពោះមុខ អ.ជ.ស.ដ នោះការដាក់ឯកសារនានាមកទល់ពេលនេះ ត្រូវ

---

កិច្ចដំណើរការនីតិវិធី ដោយជាចុងក្រោយនៅតែរក្សាការគោរពចំពោះតុលាការ")។ *រដ្ឋអាជ្ញា ទល់នឹង* *Blaškić*, IT-95-14, សាលដីកាសម្រេចលើសំណើរបស់សាធារណរដ្ឋក្រូអាត សុំឱ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៧, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៧ កថាខណ្ឌ ៣៣, ៣៥ (អំណាចជាប់មកជាមួយរបស់តុលាការ ដើម្បីធ្វើការកំណត់តាមផ្លូវតុលាការដែលចាំបាច់សម្រាប់ការអនុវត្តយុត្តាធិការបឋមរបស់ខ្លួន គឺមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងលទ្ធភាពរបស់តុលាការ នៅក្នុងការអនុវត្តបេសកកម្មដែលបានផ្តល់ឱ្យ)។ *Barayagwiza ទល់នឹង រដ្ឋអាជ្ញា*, ICTR-97-19-AR72, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩, កថាខណ្ឌ ៧៦ ("មានការទទួលស្គាល់ជាទូទៅថា តុលាការមានអំណាចគ្រប់គ្រងដែលអាចនឹងត្រូវបានប្រើប្រាស់ក្នុងផលប្រយោជន៍នៃយុត្តិធម៌ [...]។ ការប្រើប្រាស់នូវអំណាចគ្រប់គ្រងដូច្នេះបំរើឱ្យមុខងារចំនួនបី៖ ដើម្បីជាឧបាស្រ័យចំពោះការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ដើម្បីធ្វើឱ្យរាងចាលចំពោះទង្វើខុសច្បាប់នាពេលអនាគត និងដើម្បីបង្កើនសុចរិតភាពនៃដំណើរការរបស់តុលាការ")។ *រដ្ឋអាជ្ញា ទល់នឹង Karemera នឹងគូកន.*, ICTR-98-44-PT, សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង Andre Rwamakuba និងវិសោធនកម្មលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៤, កថាខណ្ឌ ២២។

[33] សំណុំរឿង ០០២-ឯកសារ **E176/2/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២, កថាខណ្ឌ ២៥ (សង្កត់ន័យដើម)។

[34] ដូចបានពិភាក្សាយ៉ាងពេញលេញនៅក្នុងឯកសារ **D359/28 & D360/37** ការឆ្លើយតបទៅនឹងវិធានការរដ្ឋបាលរបស់ ស.ព.អ, កថាខណ្ឌ ១០។ ចម្លើយតបទៅនឹងអញ្ញត្រកម្មរបស់ ស.ព.អ, កថាខណ្ឌ ១៥។ ការឆ្លើយតបទៅនឹងវិធានការរដ្ឋបាលរបស់ ស.ព.អ, កថាខណ្ឌ ៦-៨។ ឯកសារ **D359/30 & D360/39** ចម្លើយតបស្តីពីបណ្ណសាររបស់ ស.ព.អ, កថាខណ្ឌ ១៦។ ចម្លើយតបទៅនឹងអញ្ញត្រកម្មរបស់ ស.ព.អ, កថាខណ្ឌ ១២-១៥។

បានធ្វើឡើងជាសំណៅរឹងទៅកាន់ផ្នែកគ្រប់គ្រងតុលាការ ("CMS") ដោយចម្លងជូនភាគីនានា ឬក៏បានធ្វើការប្រាស្រ័យទំនាក់ទំនងគ្នាជាមួយគូភាគីតែតាមរយៈសារអេឡិចត្រូនិកប៉ុណ្ណោះ។ ស.ព.អ សន្និដ្ឋានថា គោលការណ៍តម្លាភាព និងសាធារណប្រកាស គួរតែអនុវត្ត ដូចបានទទួលស្គាល់នៅក្នុងមាត្រា ១២(២) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងវិធាន ២១(១) នៃវិធានផ្ទៃក្នុង ដើម្បីលើកកម្ពស់ភាពជឿជាក់ទៅលើដំណើរការរបស់តុលាការ។ ដោយសារមានការពាក់ព័ន្ធទៅនឹងសារសំខាន់នៃបញ្ហានេះ និងផលប្រយោជន៍ពេញសិទ្ធិរបស់សាធារណជនលើភាពរីកចម្រើននៃរឿងក្ដីទាំងនេះ ស.ព.អ នៅតែប្រកាន់ជំហររបស់ខ្លួនថា អ.ជ.ស.ដ អនុញ្ញាតឱ្យ CMS បង្កើតលេខសំណុំរឿងមួយសម្រាប់សំណុំរឿងនេះ[35] ដើម្បីឱ្យការដាក់ឯកសារនានាអាចត្រូវបានជូនដំណឹងជាផ្លូវការណ៍ដល់សាធារណជន ឬបើតាមជម្រើសផ្សេងពីនេះ សុំឱ្យការដាក់ឯកសាររបស់ ស.ព.អ ទាំងអស់រហូតមកទល់ពេលនេះ ធ្វើឱ្យទៅជាសាធារណៈទាំងអស់ ដែលអាចរកបានតាមរយៈគេហទំព័ររបស់ អ.វ.ត.ក។

## V. ឧបាស្រ័យដែលស្នើឡើង

18. អាស្រ័យដូចមូលហេតុជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិ សូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង បញ្ជាក់អំពីយុត្តាធិការរបស់ខ្លួនលើរឿងក្ដីនេះ និងសុំឱ្យអង្គជំនុំជម្រះនេះចាត់ការធ្វើយ៉ាងណាឱ្យរឿងក្ដីនេះបានទៅដល់ការជំនុំជម្រះឱ្យបានឆាប់រហ័ស តាមរយៈការបង្គាប់ឱ្យបញ្ជូនជាបន្ទាន់នូវសំណុំរឿងនេះ និងសុំឱ្យការដាក់ឯកសាររបស់ ស.ព.អ អាចរកបានជាសាធារណៈ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ | លោកស្រី Brenda J. HOLLIS<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[35] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់វិធានការ ដើម្បីទទួលបានសិទ្ធិចូលពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះ (អោ អាន) នៃសំណុំរឿង០០៤/២ និងសំណុំរឿង, ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០, កថាខណ្ឌ ៣០(គ)។